ក្នុងនោះមាន ខេត្តបាត់ដំបង ក្រចេះ បន្ទាយមានជ័យ កំពង់ចាម តាកែវ ព្រះសីហានុ កណ្តាល សៀមរាប កំពង់ឆ្នាំង កំពត កំពង់ស្ពឺ កំពង់ធំ ស្វាយរៀង ព្រៃវែង កោះកុង រតនៈគីរី ព្រះវិហារ កែប និងខេត្ត មណ្ឌលគីរី ។ សត្វកើត ជំងឺមានចំនួនជាង ២០ ០០០ ក្បាល ។

## ២. មូលហេតុ

ជំងឺសារទឹកមានលក្ខណៈរាតត្បាតខ្លាំង ក្នុងកាលៈទេសៈដែលធាតុអាកាសប្រែប្រួល ហើយមិនស្របនឹងតម្រូវការរបស់សត្វ ។ នៅពេលដែលសត្វមានសុខភាពចុះខ្សោយដោយសារប្រការផ្សេងៗ ដូចជាការហេវហត់ ការប្រើសត្វហួសកម្លាំង ការផ្តល់ចំណីមិនគ្រប់គ្រាន់ ទាំងបរិមាណ និងគុណភាព ការផ្លាស់ប្តូរចំណីអាហារ ការចាក់ថ្នាំការពារជំងឺដទៃទៀតសុទ្ធសឹងតែជា មូលហេតុបណ្តាលឱ្យមេរោគ នៃជំងឺសារទឹកឆក់ឱកាស។

## ៣-ការចម្លង និងការរាលដាល

ជំងឺសារទឹកគោ-ក្របី ឆ្លងពីសត្វមួយទៅសត្វមួយទៀត តាមរយៈការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ ឬ ភ្នាក់ងារផ្ទុកជំងឺ ការស៊ីស្មៅ ឬ រុក្ខជាតិនៅលើកន្លែងដែលមានការផ្ទុះជំងឺ និងមិនផ្ទាល់ (ពពួកបារ៉ាស៊ីត) ។





រួមគ្នាធ្វើការកំចាត់ដោយឈានទៅអនុវត្តនូវវិធានការដូចខាងក្រោម:

- សត្វឈឺចេញពីហ្វូង -កំណត់តំបន់រាតត្បាតនៃជម្ងឺឆ្លង
- រៀបចំកំណត់ព្រំដែនធ្វើចត្តាឡីស័ក្តនៅតំបន់កើតជម្ងឺឆ្លង និង តំបន់ទទួលការគំរាមកំហែង
- រៀបចំចាក់ថ្នាំការពារដល់សត្វដែលមិនទាន់ឈឺ
- ផ្សព្វផ្សាយពីប្រភពចម្លងរោគ និង របៀបចម្លងរោគដល់ប្រជា កសិករឱ្យគេយល់ច្បាស់ និង ជាពិសេសដល់អាជ្ញាធរដែនដីគ្រប់មូលដ្ឋានដើម្បីសហការកំចាត់ជម្ងឺឆ្លង
- បញ្ជូនវត្ថុវិភាគទៅមន្ទីរពិសោធន៍
- ជៀសវាងការផ្តល់ចំណីដូចជាស្មៅរុក្ខជាតិមានប្រភពពី កន្លែងកើតជំងឺ ឬ ឆ្លងជំងឺ
- ហាមចលនាសត្វចេញ-ចូល ឬឆ្លងកាត់តំបន់កើតជំងឺ
- ហាមទិញ-លក់សត្វគ្រប់ប្រភេទដែលមានជំងឺ ឬផ្ទុកមេរោគ
- ហាមប៉ះពាល់សត្វងាប់ និងពិឃាតសត្វឈឺ ឬសត្វដែលសង្ស័យ ថាឈឺ យកសាច់លក់ ឬបរិភោគ
- ដកចំណីអាហារដែលដាក់ឱ្យសត្វឈឺស៊ី ឬក្រាលឱ្យវាដេកដុត កំទេចចោល

- កន្លែងសត្វឈឺ កន្លែងទុកដាក់សម្ភារៈផ្សេងៗត្រូវធ្វើការរំងាប់មេរោគ
- រិធានការចត្តាលីស័ក្តត្រូវបានដកចេញវិញ ៣០ ថ្ងៃ ក្រោយពីបានពិនិត្យឃើញថា សត្វទាំងអស់បានជាសះស្បើយឡើងវិញដោយភ្នាក់ងារបសុពេទ្យ ។

**ឯកសារយោង:**

- របាយការណ៍បូកសរុបលទ្ធផលការងារផលិតកម្ម និងបសុព្យាបាលប្រចាំឆ្នាំ ២០០៦- ២០០៧ , ឆ្នាំ ២០០៧-២០០៨ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យចិញ្ចឹមសត្វនៅកម្ពុជាដោយវិទ្យាស្ថានជីវសាស្ត្រវេជ្ជសាស្ត្រ និងកសិកម្ម រាជបណ្ឌិត សភា ឆ្នាំ ២០០៨
- បទបង្ហាញ ស្តីពី ការយកវត្ថុវិភាគរបស់លោកស្រី រ៉េន ធារី មន្ត្រីវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល, នាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាលថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩
- បទបង្ហាញស្តីពីការពង្រឹងលើការអនុវត្តលិខិតបទដ្ឋាននៃអនុក្រឹតលេខ ២៦ អនក្រ.បកចុះថ្ងៃទី ០២ មីនា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ របស់លោកពេច ប៉េដា (២៤/០៣/០៩)
- ខិតប័ណ្ណស្តីពីអត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺសារទឹក របស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។





# ជម្ងឺសារទឹក

Haemorrhagic Septicemia (HS) (Pasteurellosis)

## ១.និយមន័យ:

ជំងឺសារទឹក ជាជំងឺឆ្លងរាតត្បាតយ៉ាងសាហាវមួយ ក្នុងចំណោមជំងឺឆ្លងនានា ។ បង្កឡើងដោយបាក់តេរីប៉ាស្ទ័ររ៉េលឡាម៉ុលតូស៊ីដា (Pasteurella Multocida) បាក់តេរីនេះមានរាងជាកូនដំបងខ្លី គ្មានចលនា និងគ្មានស្ព័រ ។ កើតឡើងលើសត្វគ្រប់ប្រភេទដូចជាគោ-ក្របី ចៀម ពពែ ជ្រូក ។ល។ បណ្តាលឱ្យមានការលាក និងជាំឈាមនៅតាមសរីរាង្គខាងក្នុងរបស់សត្វ ជាពិសេសប្រដាប់ដកដង្ហើម និងប្រដាប់រំលាយអាហារ ។ ជំងឺនេះច្រើនកើតមាននៅតំបន់ទំនាប សើមជោគជាំដក់ទឹក ពិសេសកើតមាននាដើមរដូវភ្លៀង ។ ជំងឺនេះបណ្តាលឱ្យគោ-ក្របី ងាប់យ៉ាងឆាប់រហ័ស ។ សត្វដែលឆាប់ទទួលជំងឺនេះជាងគេ គឺក្របី ជាពិសេសចំពោះសត្វក្មេងអាចទទួលជំងឺនេះយ៉ាងឆាប់រហ័ស។

ជំងឺនេះកើតមានឡើងជារៀងរាល់ឆ្នាំនៅប្រទេសកម្ពុជា។នៅឆ្នាំ២០០៨ ជំងឺសារទឹកបានកើតនៅក្នុងខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា

ត្រូវចាក់ថ្នាំការពារ ១ ឆ្នាំ ២ ដង មុនរដូវភ្លៀងធ្លាក់ក្នុងខែ ៤-៥ និង មុនរដូវក្តៅខែ ១០ ឬ ខែ ១១។




ថ្នាំការពារសត្វសំរាប់ប្រឆាំងនឹងជំងឺសារទឹកគោ-ក្របី

### ខ-វិធានការទប់ស្កាត់ជំងឺឆ្លងនៅក្នុងតំបន់កំពុងកើតជំងឺ

ក្នុងករណីមានកើតជំងឺ ឬសង្ស័យថាមានសត្វឈឺជំងឺសារទឹក ម្ចាស់សត្វ ឬម្ចាស់កសិដ្ឋានត្រូវប្រញាប់រាយការណ៍ជូនមន្ត្រីបសុពេទ្យ ឬ ភ្នាក់ងារសុខភាពសត្វភូមិដែលនៅជិតបំផុត ។ ធ្វើការកាត់ផ្តាច់ទំនាក់ទំនងរវាង សត្វឈឺនិង សត្វជានិងសត្វដែលសង្ស័យថាមានជំងឺ ។ មន្ត្រីផលិតកម្ម និង បសុព្យាបាលក្រោយពីបានទទួលដំណឹងភ្លាមចាំបាច់ត្រូវផ្សព្វផ្សាយជា បន្ទាន់ដល់អាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ និង អង្គភាពជំនាញ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ដើម្បី





ជាទូទៅសត្វគោ-ក្របី ដែលកើតជំងឺសារទឹកមានហូរទឹកមាត់ ទឹកសំបោរយ៉ាងច្រើន ដែលក្នុងនោះមានលាយឡំជាមួយបាក់តេ រីប៉ាស្ទ័ររ៉ែលឡាផងដែរទៅលើបរិស្ថានជុំវិញកន្លែងដែលវារស់នៅលើវាលស្មៅនិងក្នុងទឹក ។ល។ ជាទូទៅជំងឺនេះអាចរាតត្បាតនិងកើត ឡើងជាញឹកញាប់នៅពេលអាកាសធាតុប្រែប្រួល ជាពិសេសក្នុងរដូវ ភ្លៀងធ្លាក់ ។

## ៤- រោគសញ្ញា

- រយៈពេលមេរោគសម្ងំមានពី ២-៥ ថ្ងៃ
- សត្វអាចស្លាប់ក្នុងរយៈពេល ៦-២៤ ម៉ោង
- សត្វមានអាការៈគ្រុនក្តៅ សីតុណ្ហភាពឡើងខ្ពស់ កម្លាំងចុះខ្សោយ ចុះស្គមយ៉ាងឆាប់រហ័ស និងមានជាំឈាមនៅតាមស្រទាប់ ភ្នាសស្តើងនៃសរីរាង្គខាងក្នុង ។ តាមធម្មតាសំគាល់ឃើញហើមនៅជុំវិញ បំពង់ ក ហើយរាលដាលទៅដល់ចន្លោះជើងមុខ ឡើងទៅដល់ត្រចៀក និងជូនកាលនៅជុំវិញក្បាលទៀតផង ។ អណ្តាតអាចឡើងហើមតឹង និងលៀនចេញមកក្រៅ ភ្នែកឡើងហើម និងរលាកនៅតាមស្រទាប់ ភ្នាសស្តើងត្របកភ្នែកក្នុង ។ សត្វហើមពោះរាគឈាមលាយជាមួយ រំអិលសំបោរ រលាកសួត ជីពចរ និងដង្ហើមដើរញាប់ ។



ការហើម មុខ ក និងក្បាល



ស្នាមជាំឈាមខ្មៅនៅលើ និងក្នុងសួតសត្វ



ស្នាមជាំឈាមស្រទាប់ភ្នាសសាច់ និងស្រទាប់ភ្នាសសាច់ខាងក្នុងនៃក





# ៥- វិធានការការពារ

ក- វិធានការទប់ស្កាត់

មានសុភាសិតខ្មែរមួយឃ្លាបាននិយាយថា ″ ការពារប្រសើរជាង ការព្យាបាល″ ដូចនេះដើម្បីការពារសត្វកុំឱ្យកើតជម្ងឺសារទឹកក៏ដូចជា ជម្ងឺឆ្លងផ្សេងៗ អ្នកចិញ្ចឹមសត្វត្រូវអនុវត្តឱ្យបានល្អនូវវិធានជីវសុវត្ថិ ភាពក្នុងការចិញ្ចឹមសត្វ គោ-ក្របី ដោយៈ

- ត្រូវធ្វើអនាម័យក្រោលសត្វឱ្យបានស្អាតជានិច្ច
- ត្រូវឧស្សាហ៍ពិនិត្យគុណភាពចំណី និងតាមដានឃ្លាំមើលសុខភាពសត្វ
- ត្រូវផ្តល់ចំណី និងទឹកឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព
- វិធានការដែលមានប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺ សារទឹកគឺត្រូវចាក់វ៉ាក់សាំងការពារ ជម្ងឺ សារទឹកឱ្យសត្វ ឱ្យបានទៀងទាត់ តាមប្រតិទិនចាក់ថ្នាំការពារ ជាពិសេសចំពោះសត្វគោ-ក្របី ដែល មានអាយុក្រោម ៣ ឆ្នាំ ព្រោះសត្វជំទង់ៗងាយឆ្លងជម្ងឺនេះណាស់ ។ វ៉ាក់សាំងការពារជម្ងឺសារទឹកផ្តល់ភាពស៊ាំបានរយៈពេល ៦ ខែចំពោះថ្នាំប្រភេទរាវ និង១២ខែចំពោះប្រភេទខាប់ ។ ភាពស៊ាំមានរយៈ ពេល ៥-៧ ថ្ងៃក្រោយពីការចាក់ថ្នាំការពារជម្ងឺ ។